**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ០០៧៤/១០ .រ.ស.ស.ម

## គោរពជូន

## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន

## ប្រធានរដ្ឋសភា

**កម្មវត្ថុ** : សំណើសុំពន្យាពេលប្រជុំសភាវិសាមញ្ញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០

**យោង** : លិខិតអញ្ជើញចូលរួមប្រជុំលេខ១៥២ រ.ស ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំអ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង សូមជម្រាបជូនសម្តេចប្រធានមេត្តាជ្រាបថា នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០នេះ អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានទទួលលិខិតអញ្ជើញចូលរួមប្រជុំសភាវិសាមញ្ញ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០នេះ ដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីច្បាប់ប្រឆាំងអំពើពុករលួយ ។ ដោយយល់ឃើញថា នេះជាពេលវេលាដ៏ខ្លីដែលមិនអាចធ្វើឱ្យអ្នកតំណាងរាស្ត្រទាំងអស់ មានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យឱ្យបានល្អិតល្អន់ ទៅលើសេចក្តីព្រាងច្បាប់ដែលបានរៀបចំឡើងអស់រយៈពេលជាង១០ឆ្នាំនោះទេ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម**សម្តេចប្រធាន**មេត្តាពិនិត្យ និងឱ្យតំលៃទៅលើពេលវេលានៃការសិក្សាចំពោះសេចក្តីព្រាងច្បាប់ដ៏មានតំលៃនេះ ។

សូម **សម្តេចប្រធាន** ទទួលនូវការគោរព និងរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០

**សមាជិករដ្ឋសភា**

**យ៉ែម បុញ្ញឫទ្ធិ**

**តំណាងរាស្ត្រមណ្ឌលព្រៃវែង**

ចម្លងជូន :

- អគ្គលេខាធិការរដ្ឋសភា (ជូនជ្រាប)
- ឯកសារ និងកាលប្បវត្តិ


វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ( ៨៥៥-២៣ ) ២១៣ ៥៣៥, ២២០ ៦២៨, ទូរសារ : ( ៨៥៥-២៣ ) ២២០ ៦២៥